# ការអនុវត្តបទបញ្ជាមន្ត្រីសុខាភិបាល

ខោនធីមានបទបញ្ជានៃមន្ត្រីសុខាភិបាល (HOO) ដោយអមជាមួយនឹងពិធីសារដែលត្រូវបានចេញផ្សាយដើម្បីបន្ថយការរីករាលដាលនៃជំងឺ COVID-19។ បទបញ្ជានៃមន្ត្រីសុខាភិបាល និងពិធីសារថ្មីៗបំផុតបានចុះផ្សព្វផ្សាយនៅលើគេហទំព័រ http://ph.lacounty.gov/media/Coronavirus/reopening-la.htm។ នាយកដ្ឋានសុខភាពបរិស្ថានសាធារណៈរបស់ខោនធីត្រូវបានផ្ទេរការទទួលខុសត្រូវជាបឋមដើម្បីធានាឱ្យមានការគោរពតាមបទបញ្ជាHOO និងពិធីសារនានា។

មន្ត្រីត្រួតពិនិត្យនៃសុខភាពបរិស្ថានធ្វើទស្សនកិច្ចទីតាំងគោលដៅ៖ 1) ធានាការអនុលោមតាមបទបញ្ជា HOO និងពិធីសារដែលអាចអនុវត្តបាន 2) ដើម្បីឆ្លើយតបទៅនឹងបណ្ដឹងតវ៉ា ឬ 3) ដើម្បីស៊ើបអង្កេតរបាយការណ៍នៃការផ្ទុះជំងឺ។
គោលបំណងចម្បងនៃដំណើរទស្សនកិច្ចនីមួយៗគឺដើម្បីអប់រំប្រតិបត្តិករលើតម្រូវការអាជីវកម្មផ្សេងៗនៃបទបញ្ជាHOOដោយមានគោលដៅធានាការអនុ លោមតាមច្បាប់ដែលបានចែង។
ក្នុងករណីមានការរំលោភបំពានត្រូវបានគេសង្កេតឃើញ មន្ត្រីអធិការកិច្ចនឹងចេញរបាយការណ៍អធិការកិច្ចផ្លូវការ (របាយការណ៍ត្រួតពិនិត្យ) និងផ្តល់កាលបរិច្ឆេទដែលតម្រូវឱ្យអនុលោមតាម ដោយមានការបញ្ជាក់ថាការរំលោភគឺបានកែតម្រូវរួចរាល់ហើយ។ ការខកខានរបស់អាជីវកម្មក្នុងការកែតម្រូវតាមកាលបរិច្ឆេទនៃការអនុលោមនេះឬបន្តសកម្មភាពរំលោភម្តងហើយម្តងទៀត អាចបណ្តាលឱ្យមានសកម្មភាពអនុវត្តច្បាប់បន្ថែមទៀតរួមទាំងការវាយតម្លៃថ្លៃសេវាសម្រាប់ការធានាការអនុលោមតាមច្បាប់នេះ។

ក្នុងករណីដែលមន្ត្រីត្រួតពិនិត្យបានកំណត់នូវ**ការរំលោភបំពានដែលមានលក្ខណៈធ្ងន់ធ្ងរ** លើបទបញ្ជា HOO ឬពិធីសារផ្សេងៗនេះនឹងមានចេញលិខិតរដ្ឋបាលទទួលខុសត្រូវមួយច្បាប់ និង របាយការណ៍ត្រួតពិនិត្យ។
ការរំលោភបំពានដែលមានលក្ខណៈធ្ងន់ធ្ងរត្រូវបានកំណត់បែងចែកតាមការរីករាលដាលនៃជំងឺ COVID-19 ទៅលើនិយោជិតនិងអតិថិជន ហើយអាចបណ្តាលឱ្យមានចេញលិខិតរដ្ឋបាលទទួលខុសត្រូវមួយច្បាប់ដែលពិន័យជាប្រាក់ចំនួន ៥០០ដុល្លារនៅពេលដំណើរទស្សនកិច្ចលើកដំបូង។

**ការរំលោភបំពានដែលមានលក្ខណៈធ្ងន់ធ្ងររួមមាន៖**

- ការខកខានមិនបានអនុវត្តនៃការពិនិត្យជំងឺ COVID-19 របស់បុគ្គលិក។
- ការខកខានមិនបានរាយការណ៍នៅពេលមានករណីជំងឺ COVID-19 ចំនួន 3 ឬច្រើននាក់ដែល ត្រូវបានកំណត់អត្តសញ្ញាណនៅទីតាំងធ្វើការ។
- ការខកខានមិនបានធានាថាការពាក់របាំងមុខចំពោះបុគ្គលិកទាំងអស់ដែលតម្រូវឱ្យធ្វើដូច្នោះ។
- ការខកខានក្នុងការធានាថារបាំងគ្របមុខ ត្រូវបានពាក់ដោយនិយោជិតនៅពេលប្រាស្រ័យទាក់ទងជាមួយអតិថិជនដែលមិនពាក់ម៉ាស់ (ឧទាហរណ៍ អ្នករត់តុនៅភោជនីយដ្ឋាន)
- កង្វះឧបករណ៍សម្ភារៈសម្អាត និងសម្លាប់មេរោគនៅទីតាំងនោះ។
- លើសពីចំនួនកំណត់នៃទីតាំងទាំងមូល (រចនាសម្ព័ន្ធខាងក្រៅដែលមិនបំពេញតាមគោលការណ៍ណែនាំរបស់រដ្ឋនៃសកម្មភាពក្រៅត្រូវបានចាត់ទុកថាជាសកម្មភាព “ខាងក្នុងអគារ” ហើយរាល់វិធានការសម្រាប់សកម្មភាពនៅខាងក្នុងអគារគឺយោងទៅលើចំនួនកំណត់នៃទីតាំងទាំងមូល)
- ទោះជាគ្មានយន្តការដើម្បីតាមដានចំនួនកំណត់នៃទីតាំងនិងការធានាដើម្បីឱ្យរក្សាគម្លាត (ពោលគឺ មិនបានវាស់គម្លាតនៅគ្រប់ច្រកចូល ឬគម្លាតរាងកាយ) និងហាក់ដូចជាហួសកម្រិត - *នេះក៏អាចឈានដល់ការបិទជាបណ្តោះអាសន្នរហូតដល់ចំនួនត្រូវបានកាត់បន្ថយ ហើយដំណើរការវាស់ចម្ងាយត្រូវបានអនុវត្ត។*
- តុទាំងអស់ដែលមិនដាក់ចម្ងាយពីគ្នា 8 ហ្វីត ដូចតាមការទាមទារ។
- អតិថិជនដែលបរិភោគនៅទីតាំងដែលមិនមែនត្រូវបានកំណត់ជាទីតាំងបរិភោគ (ឧទាហរណ៍ បរិភោគអាហារដោយដើរជុំវិញទីតាំង បរិភោគនៅទីតាំងដែលបិទមិនបម្រើសេវាកម្ម ដូចជាតុតាមបារ)។
- ការកំសាន្តដោយផ្ទាល់ រួមបញ្ចូលទាំង Disk Jockey (DJ) អ្នករាំផ្ទាល់ៗ តារាកំប្លែង តន្ត្រីបន្តផ្ទាល់, ឬការកម្សាន្តផ្សេងទៀត ប៉ុន្តែមិនមែនកំណត់តែចំណុចនេះឡើយ។
- ប្រតិបត្តិការក្នុងលក្ខណៈមួយដែលបច្ចុប្បន្នត្រូវបានហាមឃាត់ (ឧទាហរណ៍ ទីតាំងនៅខាងក្នុងដែលបិទជិតយោតាមគោលការណ៍ HOO និងអាជីវកម្មដែលត្រូវបានបញ្ជាឱ្យបិទដោយសុខភាពសាធារណៈ)
- សកម្មភាពផ្សេងៗទៀតដែលរំលោភបទបញ្ជារបស់ HO ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពបុគ្គលិក ឬអតិថិជន។

លិខិតរដ្ឋបាលទទួលខុសត្រូវមួយច្បាប់អាចត្រូវបានប្តឹងឧទ្ធរណ៍ក្នុងរយៈពេល 10 ថ្ងៃបន្ទាប់ពីចេញ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖ http://publichealth.lacounty.gov/eh/citation/administrative-citation-appeals.htm. ការខកខានមិនបានបង់ជូនលិខិតរដ្ឋបាលទទួលខុសត្រូវមួយច្បាប់អាចបណ្តាលឱ្យមានការអនុវត្តវិធានការផ្លូវច្បាប់ ដែលត្រូវបានអនុញ្ញាតដោយខោនធី Los Angeles ។

សម្រាប់សំណួរផ្សេងៗស្តីពីពិធីសារ HOO និងបើកដំណើរការឡើងវិញ សូមទំនាក់ទំនងទៅកម្មវិធីការចូលរួមឧស្សាហកម្ម (Industry Engagement program) របស់យើងតាមរយៈ (626) 430-5320 ឬតាមរយៈអ៊ីម៉ែល EHConsultative@ph.lacounty.gov ដោយភ្ជាប់នឹងសំណួររបស់លោក-អ្នក។